ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

NATIONAL AIDS AUTHORITY

លេខ : ៧៥៤.................អ.ជ.ប.ជ.អ

ភ្នំពេញ, ថ្ងៃទី២១ ខែ ៧ ឆ្នាំ២០១៧

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា

## ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតប្រយុទ្ធនឹងជំងឺអេដស៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩៤២ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញប្រកាសលេខ៣៨១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ ២០១០ ស្តីពីការដាក់អោយប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ
- យោងការចាំបាច់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## សម្រេច

**ប្រការ១.** កែសម្រួលសមាសភាពគណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃ និងប្រគល់កិច្ចសន្យា (គ.ប.វ.ប PEAC) ដែលបានបង្កើតឡើងតាមប្រកាសលេខ ៥១៨ អ.ជ.ប.អ.ជ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៨ ដូចមានសមាសភាពខាងក្រោមនេះ ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **អៀង មូលី** | ទេសរដ្ឋមន្ត្រី និងជាប្រធានអ.ជ.ប.ជ.អ | ប្រធាន |
| ២- ឯកឧត្តមវេជ្ជ. | **ស៊ឹម គឹមសែន** | អនុប្រធានអ.ជ.ប.ជ.អ | អនុប្រធានទី១ |
| ៣- ឯកឧត្តមវេជ្ជ. | **តា វណា** | អនុប្រធានអ.ជ.ប.ជ.អ | អនុប្រធានទី២ |




អាសយដ្ឋាន: អគារលេខ ១៦ ផ្លូវលេខ ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់ II ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥-២៣) ៨៨៥ ១២៩

| | | | |
|---|---|---|---|
| ៤- ឯកឧត្តមសាស្ត្រាចារ្យ | **ឈី ម៉ូរ** | អនុប្រធានប្រចាំការអ.ជ.ប.ជ.អ | សមាជិក |
| ៥- ឯកឧត្តមវេជ្ជ. | **តែខ អន្ធី** | អគ្គលេខាធិការ | សមាជិក |
| ៦- ឯកឧត្តម | **តង់ វណ្ណា** | នាយកខុទ្ទកាល័យ | សមាជិក |
| ៧- ឯកឧត្តមវេជ្ជ. | **សាំង សំបូរ** | អគ្គលេខាធិការរង | សមាជិក |
| ៨- លោក | **ឌី ចាន់ម៉ុនណឿ** | ប្រធានអង្គភាពលទ្ធកម្ម | លេខាធិការ |

<u>ប្រការ២</u>. គណៈកម្មាធិការនេះ មានភារកិច្ចទទួលខុសត្រូវក្នុងការកំណត់បុរេលក្ខណៈសម្បត្តិ ការដេញថ្លៃ វាយតម្លៃលើសំណើដេញថ្លៃ និងសំណើទីប្រឹក្សា ព្រមទាំងផ្តល់អនុស្សារណៈប្រគល់កិច្ចសន្យា។

<u>ប្រការ៣</u>. រាល់ប្រកាស និងសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ៤</u>. ខុទ្ទកាល័យ អគ្គលេខាធិការដ្ឋាន ឯកឧត្តម អស់លោក លោកស្រី ដែលមានរាយនាមក្នុងប្រការ១ ត្រូវមានភារៈអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**<u>ចម្លងជូន</u>**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- ក្រសួងសុខាភិបាល
- អគ្គលេខាធិការដ្ឋានអ.ជ.ប.ជ.អ
(ដើម្បីជូនជ្រាបជាព័ត៌មាន)
- ដូចប្រការ៤
- សាមីខ្លួន
(ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ